# វិធីគាំទ្រជនរងគ្រោះ នៃអំពើហិង្សាទាក់ទង នឹងយេនឌ័រ ( GBV ) នៅពេលដែលគ្មាន តួអង្គដែលធ្វើការខាង ផ្នែក GBV ក្នុងតំបន់ របស់អ្នក

កូនសៀវភៅមគ្គុទ្ទេសក៍
ណែនាំជាជំហានៗសម្រាប់
អ្នកអនុវត្តការងារមនុស្សធម៌

# តើកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ គឺជាអ្វី?

**កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ** និងឯកសារភ្ជាប់[1] ផ្តល់ព័ត៌មានជូន**អ្នកអនុវត្តការងារមនុស្សធម៌ទាំងអស់** អំពី៖

- **របៀបគាំទ្រជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)**
- **អ្នកដែលបានប្រាប់អំពីបទពិសោធន៍នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) របស់ពួកគេឱ្យអ្នកបានដឹង**
- **នៅក្នុងបរិបទដែលគ្មានតួអង្គដែលធ្វើការងារផ្នែក GBV (រួមទាំងច្រកបញ្ជូន ឬ ជនបង្គោល GBV)។**

**កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ** នេះប្រើប្រាស់បទដ្ឋានសកលស្តីពីការផ្តល់កិច្ចគាំទ្រមូលដ្ឋាន និងព័ត៌មានជូនជនរងគ្រោះនៃGBV ដោយមិនបង្កគ្រោះថ្នាក់បន្ថែមទៀត។ យើងលើកទឹកចិត្តឱ្យកែសម្រួលធនធាននេះទៅតាមបរិបទក្នុងមូលដ្ឋានរបស់អ្នក ដោយមានកិច្ចគាំទ្រពីអ្នកឯកទេសផ្នែក GBV ក្នុងលក្ខណៈមួយដែលរក្សាបាននូវអភិក្រមផ្តោតលើជនរងគ្រោះ។

បើទោះបីជា**កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ**នេះ ប្រើប្រាស់ក្របខ័ណ្ឌជំនួយផ្នែកផ្លូវចិត្តកម្រិតបឋម (PFA) (រៀបចំ មើល ស្តាប់ និងភ្ជាប់ទំនាក់ទំនង) ក៏ដោយ ប៉ុន្តែ គេមិនចាំបាច់តម្រូវឱ្យមានចំណេះដឹង ឬការបណ្តុះបណ្តាលពីមុនអំពី PFA ឡើយ។ យ៉ាងណាមិញ សូមលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយស្តីពី PFA។

| ផ្នែក | ទំព័រ | ប្រើប្រាស់សម្រាប់ |
|---|---|---|
| សារគន្លឹះ | ២ & ៣ | ការណែនាំភ្លាមៗ |
| ដើមឈើអំពីសេចក្តីសម្រេចចិត្ត | ៤ | |
| ឯកសារព័ត៌មានអំពីសេវាដែលមាន | ៥&៦ | |
| អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ និងអ្វីដែលត្រូវនិយាយ<br>មើល<br>ស្តាប់<br>ភ្ជាប់ទំនាក់ទំនង | <br>៧<br>៨<br>៩&១០ | |
| មគ្គុទេសក៍ណែនាំជាជំហានៗ<br>ការស្វែងរកកិច្ចគាំទ្រ & កិច្ចការពារចំពោះការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ (PSEA)<br>រៀបចំ មើល ស្តាប់ និងភ្ជាប់ទំនាក់ទំនង | <br>១១<br>១២-១៥ | ការរៀបចំ និងការកសាងចំណេះដឹង និងជំនាញសម្រាប់ឆ្លើយតប |
| កុមារ និងក្មេងជំទង់ | ១៦-១៩ | ការណែនាំភ្លាមៗសម្រាប់កុមារ និង ក្មេងជំទង់អាយុក្រោម១៨ឆ្នាំ |

1 *ឯកសារភ្ជាប់ជាមួយកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ គឺជាកំណត់សម្គាល់អំពីសារវគា និងគន្លឹះសម្រាប់អ្នកប្រើប្រាស់/មគ្គុទ្ទេសក៍ណែនាំអំពីចំណេះធ្វើ។*

# សារគន្លឹះ

- **ត្រូវពិភាក្សាជាមួយអ្នកឯកទេសផ្នែក GBV ជាមុនជានិច្ច ដើម្បីស្វែងយល់អំពីសេវា GBV ដែលមាននៅក្នុងតំបន់របស់អ្នក។** សេវាមួយចំនួនអាចមានទម្រង់ជាបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ កម្មវិធីទូរស័ព្ទចល័ត ឬ កិច្ចគាំទ្រពីចម្ងាយដទៃទៀត។
- **ត្រូវដឹងអំពីសេវាដទៃទៀតដែលមាន នៅក្នុងតំបន់របស់អ្នក។** កំណត់រកសេវាដែលផ្តល់ដោយដៃគូដែលធ្វើការងារមនុស្សធម៌ ដូចជាការផ្តល់កិច្ចគាំទ្រផ្នែកសុខភាព ចិត្តសាស្ត្រ ជម្រក និងកិច្ចគាំទ្រដែលមិនមែនជាស្បៀងអាហារ។ ពិចារណាអំពីសេវាដែលផ្តល់ដោយសហគមន៍ ដូចជាវិហារឥស្លាម/វិហារ គ្រីស្តសាសនា ក្រុមស្ត្រី និងអង្គការសេវាជនពិការ។
- **ចងចាំអំពីតួនាទីរបស់អ្នក៖** ត្រូវស្តាប់ដោយមិនធ្វើការវិនិច្ឆ័យ។ ផ្តល់ព័ត៌មានដែលត្រឹមត្រូវ និងមានបច្ចុប្បន្នភាព អំពីសេវាដែលមាន។ អនុញ្ញាតឱ្យជនរងគ្រោះធ្វើការជ្រើសរើសដោយខ្លួនឯង។ ដឹងអំពីអ្វីដែលអ្នកអាច និងមិនអាចគ្រប់គ្រងបាន។ បើទោះបីជាគ្មានតួអង្គដែលធ្វើការងារផ្នែក GBV នៅក្នុងតំបន់របស់អ្នកក៏ដោយ ក៏អាចមានដៃគូដទៃទៀត ដូចជា អ្នកឯកទេសផ្នែកកិច្ចការពារកុមារ ឬ អ្នកឯកទេសផ្នែកសុខភាពផ្លូវចិត្ត ដែលអាចគាំទ្រជនរងគ្រោះដែលត្រូវការការយកចិត្តទុកដាក់ និងកិច្ចគាំទ្របន្ថែម។ ចូរសុំការអនុញ្ញាតពីជនរងគ្រោះ មុនពេលភ្ជាប់ទំនាក់ទំនងពួកគេជាមួយអ្នកដទៃ។ មិនត្រូវបង្ខំជនរងគ្រោះឡើយ ប្រសិនបើពួកគេនិយាយថា "ទេ"។
- **មិនត្រូវមានភាពប្រតិសកម្មក្នុងការខិតខំកំណត់អត្តសញ្ញាណ ឬ ស្វែងរកជនរងគ្រោះនៃ GBV ឡើយ។** ដោយឡែក ចូរត្រៀមខ្លួនក្នុងការផ្តល់ជំនួយ ក្នុងករណីដែលនរណាម្នាក់ស្នើសុំឱ្យផ្តល់កិច្ចគាំទ្រ។
- **ចូរចងចាំអំពីអាណត្តិការងាររបស់អ្នក។** រាល់អ្នកអនុវត្តការងារមនុស្សធម៌ទាំងអស់ មានអាណត្តិការងារ ក្នុងការផ្តល់កិច្ចគាំទ្រដោយមិនធ្វើការវិនិច្ឆ័យ និងគ្មានការរើសអើង ជូនដល់ជនដែលមានសេចក្តី ត្រូវការ ដោយមិនប្រកាន់អំពី ៖ យេនឌ័រ ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពពិការភាព អាយុ ជាតិពន្ធុ/កុលសម្ព័ន្ធ/សាសនា ជនប្រព្រឹត្តហិង្សា និងស្ថានភាពដែលអំពើហិង្សាត្រូវបានប្រព្រឹត្ត។

**ប្រើប្រាស់អភិក្រមផ្តោតលើជនរងគ្រោះ តាមរយៈការអនុវត្តគោលការណ៍៖**

- **ការគោរព៖** រាល់ចំណាត់ការដែលអ្នកធ្វើ ត្រូវអនុវត្តតាមគោលការណ៍នៃការគោរពចំពោះជម្រើស បំណងប្រាថ្នា សិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ។
- **សុវត្ថិភាព៖** សុវត្ថិភាពរបស់ជនរងគ្រោះគឺជាអាទិភាពទី១។
- **ការរក្សាការសម្ងាត់៖** មនុស្សមានសិទ្ធិជ្រើសរើសប្រាប់ ឬ មិនប្រាប់អំពីរឿងរ៉ាវរបស់ពួកគេទៅនរណាម្នាក់។ ការរក្សាការសម្ងាត់ មានន័យថាជាការមិនចែករំលែកព័ត៌មានណាមួយទៅនរណាម្នាក់។
- **ការមិនរើសអើង៖** ការផ្តល់ការប្រព្រឹត្តិដោយស្មើភាព និង យុត្តិធម៌ ចំពោះជនទាំងឡាយណាដែលត្រូវការកិច្ចគាំទ្រ។
- **ប្រសិនបើមានសេវាសុខភាព ត្រូវផ្តល់ព័ត៌មានអំពីអ្វីដែលមានជានិច្ច។** ចូរចែករំលែកអំពីអ្វីដែលអ្នកដឹង និងសំខាន់បំផុតគឺត្រូវពន្យល់អំពីអ្វីដែលអ្នកមិនដឹង។ ចូរអនុញ្ញាតឱ្យជនរងគ្រោះសម្រេចចិត្ត ថាតើពួកគេចង់ទទួលសេវាទាំងនោះដែរឬទេ។ ការទទួលបានការថែទាំសុខភាពប្រកបដោយគុណភាព ក្នុងរយៈពេល ៧២ម៉ោង អាចជួយបង្ការការចម្លងជំងឺកាម

រោគ និង ក្នុងរយៈពេល១២០ម៉ោង អាចជួយបង្ការការមានកូនមិនតាមប្រាថ្នា។

- ផ្តល់ឱកាសជូនជនពិការឱ្យប្រាស្រ័យទាក់ទងជាមួយអ្នក ដោយគ្មានវត្តមានអ្នកថែទាំរបស់ពួកគេ ប្រសិនបើពួកគេពួកគេចង់ធ្វើយ៉ាងដូច្នេះ និង មិនបង្កឱ្យមានគ្រោះថ្នាក់ ឬ បង្កើតភាពតានតឹងនៅក្នុងទំនាក់ទំនងនោះ។
- ប្រសិនបើបុរស ឬកុមារាម្នាក់ត្រូវបានរំលោភ ពុំមានន័យថាគាត់គឺជាអ្នកស្រឡាញ់ភេទដូចគ្នា ឬជាអ្នកដែលមានទំនោរផ្លូវភេទចំពោះបុរសផង និងស្ត្រីផងនោះទេ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ មានមូលដ្ឋានផ្អែកលើអំណាច ពុំមែនទំនោរផ្លូវភេទរបស់នរណាម្នាក់ឡើយ។
- ក្រុមដែលមានទំនោរផ្លូវភេទ និងយេនឌ័រភាគតិច រមែងតែងមានហានិភ័យប្រឈមនឹងគ្រោះថ្នាក់ និងអំពើហិង្សាខ្ពស់ ដោយសារទំនោរផ្លូវភេទ និង/ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ ចូរស្តាប់ដោយសកម្ម និងខិតខំគាំទ្រដល់ជនរងគ្រោះគ្រប់រូប។
- នរណាក៏អាចជាអ្នកប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រដែរ ក្នុងនោះរាប់បញ្ចូលទាំងប្តីប្រពន្ធ ដៃគូស្និទ្ធស្នាល សមាជិកគ្រួសារ អ្នកថែទាំ សាច់ថ្លៃ ជនចម្លែកមុខ ឪពុកឬម្តាយ ឬជនដែលផ្តល់ប្រាក់ ឬ ទំនិញអ្វីមួយ ជាថ្នូរនឹងសកម្មភាពផ្លូវភេទ។
- នរណាក៏អាចជាជនរងគ្រោះនៃអំពើហិង្សាយេនឌ័រដែរ ក្នុងនោះរួមមានជាអាទិ៍ អ្នកដែលរៀបការរួច មនុស្សចាស់ ឬ អ្នកប្រកបរបរផ្លូវភេទ និងជនដទៃទៀត។
- **ការពារអត្តសញ្ញាណ និងសុវត្ថិភាពរបស់ជនរងគ្រោះ។ មិនត្រូវកត់ត្រា ថតរូប ឬ ចែករំលែកតាមរយៈពាក្យសម្តី នូវព័ត៌មានផ្ទាល់ខ្លួន/ព័ត៌មានអត្តសញ្ញាណរបស់ជនរងគ្រោះ ឬបទពិសោធន៍របស់ពួកគេ សូម្បីតែប្រធានក្រុមរបស់អ្នកក៏ដោយ។ សូមដាក់ទូរស័ព្ទ ឬកុំព្យូទ័រទៅឱ្យឆ្ងាយ ដើម្បីជៀសវាងកុំឱ្យជនរងគ្រោះមានការព្រួយបារម្ភថាសម្លេងរបស់ពួកគេកំពុងត្រូវបានថត។**
- ព័ត៌មានផ្ទាល់ខ្លួន/ព័ត៌មានអត្តសញ្ញាណ រួមមានឈ្មោះរបស់ជនរងគ្រោះ ឈ្មោះរបស់ជនល្មើស ថ្ងៃខែឆ្នាំកំណើត លេខចុះបញ្ជី អាសយដ្ឋានកន្លែងរស់នៅ អាសយដ្ឋានកន្លែងធ្វើការ ទីតាំងដែលកូនរបស់ពួកគេទៅរៀន ពេលវេលា និងទីកន្លែងជាក់លាក់ដែលហេតុការណ៍បានកើតឡើង។ល។
- ចែករំលែកព័ត៌មានទូទៅ ដែលមិនបង្កលក្ខណៈឱ្យអាចកំណត់អត្តសញ្ញាណបាន៖
  - ជាមួយក្រុមការងាររបស់អ្នក ឬដៃគូក្នុងវិស័យការងារ ក្នុងគោលបំណងធ្វើឱ្យកម្មវិធីរបស់អ្នកកាន់តែមានសុវត្ថិភាព។
  - ជាមួយបណ្តាញគាំទ្ររបស់អ្នក នៅពេលស្វែងរកស្វ័យថែទាំ និងការលើកទឹកចិត្ត។

**"ខ្ញុំត្រូវបានប្រាប់ឱ្យដឹងថា មនុស្សកំពុងទទួលរងការបៀតបៀននៅជុំវិញកន្លែងចំណុចប្រភពទឹក ដោយសារវាគឺជាកន្លែងដែលស្ថិតនៅឆ្ងាយដាច់ដោយឡែកពីគេឯង។ យើងអាចព្យាយាមកាត់បន្ថយការបៀតបៀននេះ តាមរយៈការលើកទឹកចិត្តឱ្យប្រើប្រាស់ចំណុចប្រភពទឹកដែលនៅជិត ឬលើកទឹកចិត្តឱ្យទៅដងទឹកជាក្រុម ឬ ...."**

**"មានមនុស្សម្នាក់ចែករំលែកជាមួយខ្ញុំនូវបទពិសោធន៍អាក្រក់មួយដែលបានកើតឡើងចំពោះគាត់។ ខ្ញុំមិនអាចប្រាប់អំពីព័ត៌មានលម្អិតបានទេ ប៉ុន្តែ ត្រូវការកិច្ច គាំទ្រពាក់ព័ន្ធនឹងរបៀបដែលការប្រាស្រ័យទាក់ទងនេះបង្កឱ្យមានផលប៉ះពាល់ដល់ខ្ញុំ។"**



# ដើមឈើអំពីសេចក្តីសម្រេចចិត្ត

សម្រាប់កុមារ និង ក្មេងជំទង់ សូមមើលទំព័រ ១៦។

## រៀបចំ

ត្រូវដឹងអំពីសេវាដែលមានស្រាប់

**គេបានប្រាប់ហេតុការណ៍ GBV មួយឱ្យអ្នកដឹង...**

**ដោយនរណាម្នាក់...**
ផ្តល់ព័ត៌មានប្រកបដោយបច្ចុប្បន្នភាព និងសុក្រឹត្យអំពីសេវា និងកិច្ចគាំទ្រនានាដែលអាចមាន សម្រាប់ជនរងគ្រោះ។លើកទឹកចិត្តបុគ្គលឱ្យចែករំលែកព័ត៌មាននេះដោយសុវត្ថិភាព និងរក្សាការសម្ងាត់ ជាមួយជនរងគ្រោះ ដើម្បីឱ្យពួកគេអាចប្រាប់ទៅតាមឆន្ទៈរបស់ពួកគេ។
***សម្គាល់៖ មិនត្រូវស្វែងរកជនរងគ្រោះនៃ GBV ឡើយ។***

**ដោយជនរងគ្រោះ**
**មើល និង ស្តាប់**
( សូមមើលទំព័រ ៧ & ៨ )
ណែនាំខ្លួនអ្នកឱ្យគេស្គាល់។ សួរថាតើអ្នកអាចជួយពួកគេបានយ៉ាងដូចម្តេច។ អនុវត្តគោលការណ៍នៃការគោរព សុវត្ថិភាព ការរក្សាការសម្ងាត់ និង ការមិនរើសអើង។

**តើមានតួអង្គដែលធ្វើការងារផ្នែក GBV/ច្រកបញ្ជូន ដែរឬទេ?**

**មាន។** អនុវត្តតាមច្រកបញ្ជូនករណី GBV ដើម្បីប្រាប់ជនរងគ្រោះអំពីសេវា GBV ដែលមាន និងធ្វើការបញ្ជូនប្រសិនបើជនរងគ្រោះអនុញ្ញាត។

**គ្មាន។ ភ្ជាប់ទំនាក់ទំនង**
( សូមមើលទំព័រ ៩ និង ១០ )
ផ្តល់ព័ត៌មានត្រឹមត្រូវអំពីសេវាដែលមាន

**តើជនរងគ្រោះជ្រើសរើសឱ្យភ្ជាប់ទំនាក់ទំនងទៅនឹងសេវា ដែរឬទេ?**

**ព្រម។** ប្រាប់ព័ត៌មានលម្អិតអំពីធនធាន/សេវាដែលមាន រាប់បញ្ចូលទាំងរបៀបទទួលបានសេវា ពេលវេលាពាក់ព័ន្ធ និង ទីតាំង ជនបង្គោលនៅឯកន្លែងផ្តល់សេវា ជម្រើសធ្វើដំណើរប្រកបដោយសុវត្ថិភាព។ល។ មិនត្រូវចែករំលែកព័ត៌មានអំពីជនរងគ្រោះ ឬ បទពិសោធន៍របស់ពួកគេឱ្យនរណាម្នាក់បានដឹង ដោយគ្មានការយល់ព្រមច្បាស់លាស់ ក្រោមមូលដ្ឋាននៃការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយពីជនរងគ្រោះ។ មិនត្រូវកត់ត្រាសេចក្តីលម្អិតអំពីហេតុការណ៍ ឬ ព័ត៌មានកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះឡើយ។

**មិនព្រម។** រក្សាការសម្ងាត់។ ចូរពន្យល់ថាជនរងគ្រោះអាចប្តូរចិត្តរបស់ពួកគេ និងស្វែងរកសេវានៅពេលក្រោយបាន។ ប្រសិនបើសេវាមានផ្តល់ជូនបណ្តោះអាសន្ន ជាសេវាចល័ត ឬ មានសម្រាប់តែរយៈពេលកំណត់ណាមួយ ចូរផ្តល់ព័ត៌មានថាតើសេវាទាំងនេះនឹងលែងមានសម្រាប់ផ្តល់ជូន ដែរឬទេ។

*Adapted from the Shelter Cluster's GBV Constant Companion (www.sheltercluster.org/gbv).*

# ឯកសារព័ត៌មាន

សូមបំពេញឯកសារព័ត៌មាននេះសម្រាប់សេវានៅក្នុងតំបន់របស់អ្នក និង ទុកវានៅកន្លែងដែលងាយមើលឃើញ។

ធ្វើការងារជាមួយអ្នកឯកទេសផ្នែក GBV ប្រធានក្រុម និង ដៃគូរបស់អ្នក ដើម្បីកំណត់រក (១) សេវាដែលមានផ្តល់ដោយដៃគូធ្វើការងារផ្នែកមនុស្សធម៌ និង (២) សេវាតាមសហគមន៍ ដូចជាក្រុមសាសនា/កន្លែងថ្វាយបង្គំ ក្រុមស្ត្រី អង្គការជនពិការ។ល។

| | | |
|---|---|---|
| **កិច្ចការពារកុមារ** | ព័ត៌មាន | |
| | ជនបង្គោល | |
| **កិច្ចគាំទ្រសុខភាពផ្លូវចិត្ត/ចិត្តសង្គម** | ព័ត៌មាន | |
| | ជនបង្គោល | |
| **សុខភាព** | ព័ត៌មាន | |
| | ជនបង្គោល | |
| **សុខភាពផ្លូវភេទ និង សុខភាពបន្តពូជ** | ព័ត៌មាន | |
| | ជនបង្គោល | |
| **កិច្ចគាំទ្រដែលមិនមែនជាស្បៀងអាហារ// WASH រួមទាំងកញ្ចប់សម្ភារៈអនាម័យ** | ព័ត៌មាន | |
| | ជនបង្គោល | |
| **ជម្រក** | ព័ត៌មាន | |
| | ជនបង្គោល | |

| | | |
|---|---|---|
| ច្បាប់ | ព័ត៌មាន | |
| | ជនបង្គោល | |
| ស្បៀង និង អាហារូបត្ថម្ភ | ព័ត៌មាន | |
| | ជនបង្គោល | |
| សេវាសម្រាប់ ក្មេងជំទង់/យុវជន | ព័ត៌មាន | |
| | ជនបង្គោល | |
| សេវាសម្រាប់ជនពិការ | ព័ត៌មាន | |
| | ជនបង្គោល | |
| សេវាសម្រាប់ក្រុម ដែលមានទំនោផ្លូវភេទ និង យេនឌ័រភាគតិច | ព័ត៌មាន | |
| | ជនបង្គោល | |
| សេវាសម្រាប់កុមារ ឬ ស្ត្រីជាមេគ្រួសារ | ព័ត៌មាន | |
| | ជនបង្គោល | |
| ផ្សេងៗ | ព័ត៌មាន | |
| | ជនបង្គោល | |
| ផ្សេងៗ | ព័ត៌មាន | |
| | ជនបង្គោល | |

# អ្វីដែលត្រូវធ្វើ អ្វីដែលមិនត្រូវធ្វើ និង អ្វីដែលត្រូវនិយាយ

សម្រាប់កុមារ និងក្មេងជំទង់ សូមមើលទំព័រ ១៦។

## មើល

| អ្វីដែលត្រូវធ្វើ | អ្វីដែលមិនត្រូវធ្វើ |
|---|---|
| ✓ អនុញ្ញាតឱ្យជនរងគ្រោះទាក់ទងមកអ្នក។ ស្តាប់អំពីសេចក្តីត្រូវការរបស់ពួកគេ។ | × មិនត្រូវមិនអើពើចំពោះនរណាម្នាក់ដែលមកទាក់ទងអ្នក និងប្រាប់អ្នកឱ្យដឹងថាគាត់បានទទួលរងបទពិសោធន៍អាក្រក់ បទពិសោធន៍ដែលបង្កឱ្យគាត់មិនស្រណុកក្នុងខ្លួន អ្វីម៉្យាងដែលមិនត្រឹមត្រូវ និង/ឬ អំពើហិង្សាឡើយ។ |
| ✓ សួរថាតើអ្នកអាចផ្តល់ការគាំទ្រសម្រាប់សេចក្តីត្រូវការមូលដ្ឋានជាបន្ទាន់ ដោយរបៀបណា។ ជនរងគ្រោះមួយចំនួន អាចត្រូវការការថែទាំសុខភាព ឬសម្លៀកបំពាក់ភ្លាមៗ។ | × មិនត្រូវបង្ខំផ្តល់ជំនួយជូនជនរងគ្រោះ ដោយការជ្រៀតជ្រែក ឬ ជម្រុញឡើយ។ |
| ✓ ចូរសួរជនរងគ្រោះ ថាតើពួកគេមានអារម្មណ៍ងាយស្រួលក្នុងការនិយាយជាមួយអ្នក នៅឯទីកន្លែងបច្ចុប្បន្នរបស់អ្នកដែរទេ។ ប្រសិនបើជនរងគ្រោះមាននរណាម្នាក់អមមកជាមួយ ចូរកុំសន្និដ្ឋានថាមានសុវត្ថិភាពក្នុងការនិយាយជាមួយជនរងគ្រោះអំពីបទពិសោធន៍របស់ពួកគេ នៅចំពោះមុខជនម្នាក់នោះ។ | × មិនត្រូវប្រតិកម្មហួសប្រមាណឡើយ។ ចូរបន្តរក្សាភាពស្ងប់ស្ងាត់។ |
| ✓ ចូរផ្តល់កិច្ចគាំទ្រជាក់ស្តែងដូចជា ការផ្តល់ទឹកផឹក កន្លែងឯកជនសម្រាប់អង្គុយ ក្រដាសអនាម័យ។ល។ | × មិនត្រូវដាក់សម្ពាធជនរងគ្រោះ ឱ្យចែករំលែកព័ត៌មានបន្ថែម លើសពីអ្វីដែលពួកគេមានអារម្មណ៍ងាយស្រួលក្នុងការចែករំលែកឡើយ។ សេចក្តីលម្អិតអំពីអ្វីដែលបានកើតឡើង និងនរណាជាអ្នកប្រព្រឹត្ត មិនសំខាន់ ឬ ពាក់ព័ន្ធចំពោះតួនាទីរបស់អ្នក ក្នុងការស្តាប់ និង ផ្តល់ព័ត៌មានអំពីសេវាដែលមានឡើយ។ |
| ✓ ទៅតាមលទ្ធភាពរបស់អ្នក ចូរសូមឱ្យជនរងគ្រោះជ្រើសរើសនរណាម្នាក់ដែលគាត់មានអារម្មណ៍ងាយស្រួលជាមួយ ដើម្បីបកប្រែជូនគាត់ និង/ឬ គាំទ្រគាត់ក្នុងករណីចាំបាច់។ | × មិនត្រូវសួរថាតើនរណាម្នាក់ធ្លាប់ទទួលរងបទពិសោធន៍នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ធ្លាប់ត្រូវបានគេរំលោភសេពសន្ថវៈ វាយដំ...។ល។ ឡើយ។ |

### ឧទាហរណ៍នៃអ្វីដែលត្រូវនិយាយ.....

- "អ្នកហាក់បីដូចជាកំពុងមានការឈឺចាប់ខ្លាំងណាស់នៅពេលនេះ តើអ្នកចង់ទៅពេទ្យដែរឬទេ ?"
- "តើអ្នកមានអារម្មណ៍ងាយស្រួលចំពោះកន្លែងនេះ ដែរឬទេ ? តើមានកន្លែងណាផ្សេងទៀត ដែលនឹងធ្វើឱ្យអ្នកមានអារម្មណ៍ល្អជាងនេះ ដែរឬទេ ? តើអ្នកមានអារម្មណ៍ងាយស្រួលក្នុងការជជែកគ្នានៅកន្លែងនេះ ដែរឬទេ ?"
- "តើអ្នកចង់ញ៉ាំទឹក ដែរឬទេ ? សូមអង្គុយលេងដោយសេរី។"

# ស្តាប់

| អ្វីដែលត្រូវធ្វើ | អ្វីដែលមិនត្រូវធ្វើ |
|---|---|
| ✓ ត្រូវរក្សាការសម្ងាត់ចំពោះរាល់ព័ត៌មានដែលបានចែករំលែកជាមួយអ្នក។ ប្រសិនបើអ្នកចង់សុំជំនួយ និងការណែនាំអំពីរបៀបគាំទ្រជនរងគ្រោះឱ្យបានល្អបំផុត ចូរសុំការអនុញ្ញាតពីជនរងគ្រោះដើម្បីឱ្យអ្នកជជែកជាមួយអ្នកឯកទេស ឬ សហការីរបស់អ្នក។ ចូរធ្វើបែបនេះ ដោយមិនបង្ហាញអំពីព័ត៌មានកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះ។ | × មិនត្រូវកត់ត្រា ថតរូបរបស់ជនរងគ្រោះ ថតកិច្ចសន្ទនាដោយប្រើទូរស័ព្ទរបស់អ្នក ឬ ឧបករណ៍ដទៃ ឬ ប្រាប់ឱ្យអ្នកដទៃបានដឹងឡើយ រួមទាំងប្រព័ន្ធផ្សព្វផ្សាយ។ |
| ✓ ចូររៀបចំការរំពឹងទុកនានា ក្រោមដែនកំណត់នៃការរក្សាការសម្ងាត់របស់អ្នក ប្រសិនបើអាចអនុវត្តបាននៅក្នុងបរិបទរបស់អ្នក។[2] | × មិនត្រូវសួរសំនួរអំពីអ្វីដែលបានកើតឡើងឡើយ។ ដោយឡែក ចូរស្តាប់ និងសួរអ្វីដែលអ្នកអាចធ្វើបានដើម្បីផ្តល់ការគាំទ្រ។ |
| ✓ ចូរគ្រប់គ្រងការរំពឹងទុកចំពោះតួនាទីរបស់អ្នក។ | × មិនត្រូវធ្វើការប្រៀបធៀបរវាងបទពិសោធន៍របស់ជនរងគ្រោះទៅនឹងអ្វីដែលបានកើតឡើងចំពោះអ្នកដទៃទៀតឡើយ។ មិនត្រូវនិយាយថាស្ថានភាពនេះ "មិនមែនជារឿងធំដុំ" ឬ មិនសំខាន់ឡើយ។ អ្វីដែលជាបញ្ហានោះគឺតើជនរងគ្រោះមានអារម្មណ៍ដូចម្តេចចំពោះបទពិសោធន៍របស់ពួកគេ។ |
| ✓ ចូរស្តាប់ឱ្យបានច្រើនជាងអ្នកនិយាយ។ | × មិនត្រូវមានមន្ទិល ឬ និយាយផ្ទុយពីអ្វីដែលនរណាម្នាក់បានប្រាប់អ្នកឡើយ។ ចូរចងចាំថាតួនាទីរបស់អ្នកគឺត្រូវស្តាប់ដោយមិនធ្វើការវិនិច្ឆ័យ និង ផ្តល់ព័ត៌មានអំពីសេវាដែលមាន។ |
| ✓ ចូរនិយាយប្រយោគមួយចំនួនដែលផ្តល់ការលួងលោម និង ផ្តល់កិច្ចគាំទ្រ ដោយបញ្ជាក់ថាអ្វីដែលបានកើតឡើងចំពោះពួកគេ មិនមែនជាកំហុសរបស់ពួកគេឡើយ។ | |

## ឧទាហរណ៍នៃអ្វីដែលត្រូវនិយាយ.....

- "តើខ្ញុំអាចគាំទ្រអ្នកបានដោយរបៀបណា?"
- "គ្រប់យ៉ាងដែលយើងនិយាយគ្នា នឹងរក្សាជាការសម្ងាត់រវាងយើងពីរនាក់ប៉ុណ្ណោះ។ ខ្ញុំនឹងមិនប្រាប់ទៅអ្នកដទៃដោយគ្មានការអនុញ្ញាតពីអ្នកឡើយ។"
- "ខ្ញុំនឹងព្យាយាមគាំទ្រអ្នក ឱ្យបានច្រើនបំផុតទៅតាមដែលអាចធ្វើទៅបាន ប៉ុន្តែខ្ញុំមិនមែនជាអ្នកផ្តល់ប្រឹក្សាយោបល់នោះទេ។ ខ្ញុំអាចចែករំលែករាល់ព័ត៌មានដែលខ្ញុំមានអំពីកិច្ចគាំទ្រដែលមាន ឱ្យអ្នកបានដឹង។"
- "សូមប្រាប់ខ្ញុំឱ្យដឹងនូវអ្វីដែលអ្នកចង់ប្រាប់។ អ្នកមិនចាំបាច់ប្រាប់ឱ្យខ្ញុំដឹងអំពីបទពិសោធន៍ ដែលអ្នកបានជួបប្រទះ ដើម្បីឱ្យខ្ញុំអាចផ្តល់ព័ត៌មានជូនអ្នកអំពីកិច្ចគាំទ្រដែលមានសម្រាប់អ្នកនោះទេ។"
- "ខ្ញុំសោកស្តាយណាស់ដែលរឿងនេះបានកើតឡើងចំពោះអ្នក។"
- "អ្វីដែលបានកើតឡើង មិនមែនជាកំហុសរបស់អ្នកទេ។"

*2 មានបរិបទមួយចំនួន ដែលមានវិធាននៃការផ្តល់របាយការណ៍ជាកាតព្វកិច្ច ទាក់ទងនឹងប្រភេទករណីជាក់លាក់មួយចំនួន។ សូមសាកសួរជនបង្គោលទទួលបន្ទុកកិច្ចការពារ និង/ឬ អ្នកឯកទេសផ្នែក GBV សម្រាប់ព័ត៌មាន និងការណែនាំបន្ថែម។*

# ភ្ជាប់ទំនាក់ទំនង

## អ្វីដែលត្រូវធ្វើ

- ✓ ត្រូវគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការសម្រេចចិត្តដោយខ្លួនឯង។
- ✓ ត្រូវចែករំលែកព័ត៌មានអំពីរាល់សេវាទាំងអស់ដែលអាចមាន បើទោះបីជា ពុំមែនជាសេវាឯកទេសផ្នែក GBV ក៏ដោយ។
- ✓ ត្រូវប្រាប់ជនរងគ្រោះថា គាត់មិនចាំបាច់ត្រូវសម្រេចចិត្តឥឡូវនេះទេ ដោយគាត់អាចប្ដូរចិត្ត និងទទួលសេវាទាំងនេះនៅពេលក្រោយបាន។
- ✓ ត្រូវសួរថាតើមាននរណាម្នាក់ ដូចជា មិត្តភក្តិ សមាជិកគ្រួសារ អ្នកថែទាំ ឬនរណាម្នាក់ផ្សេងទៀត ដែលជនរងគ្រោះទុកចិត្ត ដែលអាចទាក់ទងបាន ដើម្បីផ្តល់ការគាំទ្រ ដែរឬទេ។
- ✓ ត្រូវផ្តល់ទូរស័ព្ទរបស់អ្នក ឬ ឧបករណ៍ទំនាក់ទំនងដទៃទៀត (ប្រសិនបើអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការធ្វើបែបនេះ) ជូនជនរងគ្រោះដើម្បីទាក់ទងនរណាម្នាក់ដែលគាត់ទុកចិត្ត។
- ✓ ត្រូវសុំការអនុញ្ញាតពីជនរងគ្រោះមុនពេលចាត់វិធានការនានា។
- ✓ ត្រូវបញ្ចប់កិច្ចសន្ទនាក្នុងលក្ខណៈដែលផ្តល់ការគាំទ្រ។



## អ្វីដែលមិនត្រូវធ្វើ

- × មិនត្រូវអួតអាងពីជំនាញរបស់អ្នក សន្យាខ្យល់ ឬផ្តល់ព័ត៌មានក្លែងក្លាយនោះទេ។
- × មិនត្រូវផ្តល់ដំបូន្មាន ឬ គំនិតផ្ទាល់ខ្លួនអំពីកម្រង សកម្មភាពល្អបំផុត ឬ អ្វីដែលត្រូវធ្វើបន្ទាប់ទៀតឡើយ។
- × មិនត្រូវសន្មតថាអ្នកដឹងអំពីអ្វីដែលនរណាម្នាក់ចង់បាន ឬ ត្រូវការឡើយ។ សកម្មភាពមួយចំនួនអាចធ្វើឱ្យនរណាម្នាក់កាន់តែមានការប្រឈមទៅនឹងការមាក់ងាយ ការសងសឹក ឬ គ្រោះថ្នាក់។
- × មិនត្រូវសន្និដ្ឋានអំពីនរណាម្នាក់ ឬ បទពិសោធន៍របស់ពួកគេនោះទេ និង មិនត្រូវរើសអើងឡើយ ទោះក្រោមហេតុផលណាក៏ដោយ រួមទាំងអាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ពិការភាព សាសនា ជាតិពន្ធុ វណ្ណៈ ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ អត្តសញ្ញាណរបស់ជនល្មើស។ល។
- × មិនត្រូវព្យាយាមបង្កើតសន្តិភាព ផ្សះផ្សារ ឬ ដោះស្រាយស្ថានភាព រវាងអ្នកដែលបានទទួលរងបទពិសោធន៍ GBV និង មនុស្សម្នាក់ទៀត (ដូចជា ជនល្មើស ឬជនទីបីណាម្នាក់ ដូចជាសមាជិកគ្រួសារ សមាជិកគណៈកម្មការសហគមន៍ មេដឹកនាំសហគមន៍។ល។) ឡើយ។
- × មិនត្រូវចែករំលែកព័ត៌មានលម្អិតអំពីហេតុការណ៍ និង ព័ត៌មានអត្តសញ្ញាណបុគ្គលរបស់ជនរងគ្រោះជាមួយ នរណាម្នាក់ឡើយ។ ក្នុងនោះរួមមាន សមាជិកគ្រួសាររបស់ជនរងគ្រោះ កងកម្លាំងនគរបាល/ សន្តិសុខ មេដឹកនាំសហគមន៍ សហការីប្រធានក្រុម។ល។ ការចែករំលែកព័ត៌មាននេះ អាចនាំឱ្យកាន់តែមានគ្រោះថ្នាក់ចំពោះជនរងគ្រោះ។
- × មិនត្រូវសួរអំពីជនរងគ្រោះ ឬ ទាក់ទងជនរងគ្រោះក្រោយពេលដែលអ្នកបានបញ្ចប់កិច្ចសន្ទនាឡើយ។

**ឧទាហរណ៍នៃអ្វីដែលត្រូវនិយាយ........**

- "កិច្ចសន្ទនារបស់យើង នឹងរក្សាជាការសម្ងាត់រវាងយើងតែប៉ុណ្ណោះ។"
- "ខ្ញុំមិនមែនជាអ្នកផ្តល់ប្រឹក្សាយោបល់ទេ ប៉ុន្តែខ្ញុំអាចផ្តល់ឱ្យអ្នកនូវព័ត៌មានដែលខ្ញុំមាន។ មានមនុស្ស/អង្គការមួយចំនួនដែលអាចផ្តល់កិច្ចគាំទ្រមួយចំនួនជូនអ្នក និង/ឬ គ្រួសាររបស់អ្នកបាន។ តើអ្នកចង់ដឹងព័ត៌មានអំពីពួកគេ ដែរឬទេ ?"
- "នេះគឺជាព័ត៌មានលម្អិតនៃសេវា រួមទាំងទីតាំង និងពេលវេលា ដែលគេបើកទ្វារផ្តល់សេវា ថ្លៃចំណាយ (ប្រសិនបើមាន) ជម្រើសក្នុងការធ្វើដំណើរ និង ឈ្មោះរបស់បុគ្គលដែលអ្នកអាចនិយាយជាមួយ។"
- "តើមាននរណាម្នាក់ដែលអ្នកទុកចិត្ត និង អាចទៅសុំការគាំទ្របានដែរឬទេ ឧទាហរណ៍ ដូចជាសមាជិកគ្រួសារ ឬ មិត្តភក្តិ? តើអ្នកចង់ប្រើទូរស័ព្ទរបស់ខ្ញុំដើម្បីទាក់ទងទៅនរណាម្នាក់ដែលអ្នកត្រូវការ នៅពេលនេះដែរឬទេ ?"
- "នៅពេលដែលឈានដល់ជំហានបន្ទាប់ អ្វីដែលអ្នកចង់បាន និងអ្វីដែលធ្វើឱ្យអ្នកមានអារម្មណ៍ងាយស្រួល គឺជាការពិចារណាដ៏សំខាន់បំផុត។"
- "កុំមានអារម្មណ៍ថាមានសម្ពាធ ក្នុងការដែលត្រូវសម្រេចចិត្តនៅពេលនេះ។ អ្នកអាចគិតសិន និងប្តូរចិត្តរបស់អ្នកនៅពេលក្រោយបាន។"
- "ខ្ញុំមិនអាចនិយាយជាមួយនរណាម្នាក់ជំនួសអ្នក ដើម្បីព្យាយាមដោះស្រាយស្ថានភាពបានទេ។ ប៉ុន្តែអ្វីដែលខ្ញុំអាចធ្វើបានគឺគាំទ្រអ្នកក្នុងពេលដែលយើងកំពុងសន្ទនា និងស្តាប់បញ្ហាកង្វល់របស់អ្នក។"
- "ស្តាប់មើលទៅ អ្នកហាក់បីដូចជាមានផែនការសម្រាប់ពេលនេះរហូតដល់ថ្ងៃមុខរួចទៅហើយ។ នេះគឺជាជំហានវិជ្ជមានមួយ។"

# ការយល់ឃើញរបស់ជនរងគ្រោះ

## ប្រយោជន៍ និង ហានិភ័យនៃការស្វែងរកកិច្ចគាំទ្រ

ការស្វែងរកសេវាមិនមែនសុទ្ធតែមានសុវត្ថិភាពសម្រាប់ជនរងគ្រោះឡើយ និងអាចនាំឱ្យកាន់តែមានគ្រោះថ្នាក់។ សូមចងចាំថា តួនាទីរបស់អ្នកគឺផ្តល់ព័ត៌មានត្រឹមត្រូវ និងមានបច្ចុប្បន្នភាព អំពីសេវាដែលមាន និងអនុញ្ញាតឱ្យជនរងគ្រោះធ្វើការជ្រើសរើសដោយខ្លួនឯង អំពីអ្វីដែលពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព។ ចូរពិចារណាអំពីឧទាហរណ៍ខាងក្រោម អំពីអត្ថប្រយោជន៍ និងហានិភ័យ៖

### ហានិភ័យនៃការស្វែងរកកិច្ចគាំទ្រ

- មានលទ្ធភាពដែលមិត្តភក្តិ គ្រួសារ និង/ឬ សហគមន៍របស់ជនរងគ្រោះអាចដឹង ដែលអាចនាំឱ្យមានការមាក់ងាយ បណ្តេញចេញពីផ្ទះ ឬ សហគមន៍ និង/ឬ ប្រឈមទៅនឹងហិង្សា បន្ថែមទៀត។
- មានលទ្ធភាពដែលជនល្មើសអាចដឹង ថាមានអ្នកដទៃដឹងអំពីរឿងហេតុដែលបានកើតឡើង ដែលនាំឱ្យមានការសងសឹក តាមរយៈការបង្កគ្រោះថ្នាក់ ឬ សម្លាប់ជនរងគ្រោះ។
- មានលទ្ធភាពដែលអ្នកផ្តល់សេវា អាចប្រឈមទៅនឹងការគំរាមកំហែង និង អំពើហិង្សាពីជនល្មើស ឬ សហគមន៍ ប្រសិនបើពួកគេត្រូវបានមើលឃើញថាកំពុងជួយដល់ជនរងគ្រោះ។
- មានលទ្ធភាពដែលអ្នកផ្តល់សេវា អាចផ្តល់ការឆ្លើយតបដោយមិនបានគិតគូយកចិត្តទុកដាក់ គ្រប់ជ្រុងជ្រោយ ប្រសិនបើពួកគេមិនបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។

### អត្ថប្រយោជន៍នៃការស្វែងរកកិច្ចគាំទ្រ

- ការទទួលបានកិច្ចគាំទ្រសង្គ្រោះជីវិតនៅពេលមានវិបត្តិ។
- ការទទួលបានការថែទាំសុខភាពទាន់ពេលវេលា ប្រកបដោយសុវត្ថិភាព រក្សាការសម្ងាត់ និងមានភាពវិជ្ជាជីវៈ ដែលអាចបង្ការមេរោគអេដស៍ និងការមានកូនមិនតាមប្រាថ្នា។
- ការទទួលបានសេវាដទៃទៀត ដែលផ្តល់នូវសេចក្តីថ្លៃថ្នូរ និង ផាសុកភាព រួមទាំងជម្រើសសម្រាប់សុវត្ថិភាព និងកិច្ចគាំទ្រផ្នែកចិត្តសង្គម។
- ការទទួលបានកិច្ចគាំទ្រដែលអាចបង្ការអំពើហិង្សាមិនឱ្យកើតឡើងទៀត។

### ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ដោយតួអង្គដែលធ្វើការងារផ្នែកមនុស្សធម៌ ឬ បុគ្គលដែលពាក់ព័ន្ធនឹងជំនួយមនុស្សធម៌

កិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (PSEA) គឺជាវាក្យស័ព្ទមួយដែលត្រូវបានប្រើ ដើម្បីសំដៅចំពោះជំហាននានា ដែលត្រូវបានអនុវត្តដោយតួអង្គដែលធ្វើការងារផ្នែកមនុស្សធម៌ ឬ បុគ្គលិកពាក់ព័ន្ធ ដើម្បីការពារជនងាយរងគ្រោះពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ក្នុងនោះរួមមានបុគ្គលិកជំនួយមនុស្សធម៌ កងកម្លាំងរក្សាសន្តិភាព អ្នកផ្គត់ផ្គង់ទំនិញ និងសេវាសម្រាប់គោលបំណងមនុស្សធម៌។ល។

មិនចំពោះថាជនល្មើសជានរណាក៏ដោយ ផែនទីបង្ហាញផ្លូវសម្រាប់គាំទ្រជនរងគ្រោះនៃ GBV ដូចមាន គូសបញ្ជាក់នៅក្នុងឯកសារនេះ នៅតែបន្តមានលក្ខណៈដដែល។ សម្រាប់ការទទួលខុសត្រូវបន្ថែម ដែលកើតមាន នៅពេលដែលជនល្មើសគឺជាបុគ្គលិកផ្តល់ជំនួយ ឬ ពាក់ព័ន្ធនឹងជំនួយមនុស្សធម៌ សូមទាក់ទងជនបង្គោល PSEA របស់អ្នក ឬ បណ្តាញ PSEA ក្នុងប្រទេស។

## រៀបចំ

**ការរៀបចំគឺជាគន្លឹះមួយដ៏សំខាន់។** បើទោះបីជាគ្មានតួអង្គដែលធ្វើការងារផ្នែក GBV (រាប់បញ្ចូលទាំងច្រកបញ្ជូន GBV ឬ ជនបង្គោល GBV) នៅក្នុងតំបន់របស់អ្នកក៏ដោយ ក៏អាចមានសេវាដទៃទៀត រួមទាំងនៅកម្រិតមូលដ្ឋាន/សហគមន៍ ដែលអាចជួយដោះស្រាយ សេចក្តីត្រូវការរបស់នរណាម្នាក់បាន។ អ្នកទំនងជាដឹងអំពីសេវាជាច្រើនជាងការដែលអ្នកគិត!

### ត្រូវដឹងអំពីសេវាដែលមាន

- ប្រើប្រាស់**ទំរង់ស្រង់ឯកសារព័ត៌មាន (ទំព័រ ៥ និង៦)** ដើម្បីបំពេញព័ត៌មានអំពីសេវាដែលមាន។ ចូរធ្វើការងារជាមួយអ្នកឯកទេសផ្នែកយេនឌ័រ ប្រធានក្រុមរបស់អ្នក សហការី និងដៃគូដទៃទៀត។ ចូរកត់ត្រាព័ត៌មាន ចាំបាច់នានា អំពីរបៀបទទួលបានសេវាទាំងនោះ រួមទាំងតើត្រូវទៅកន្លែងណា តើត្រូវនិយាយជាមួយនរណា និងតើនរណាខ្លះដែលអាច/មិនអាចទទួលបានសេវាទាំងនោះ (ឧ. សម្រាប់តែស្ត្រី ឯកសារចាំបាច់នានា។ល។)។
- សួរប្រធានក្រុមរបស់អ្នក ប្រធានគ្រប់គ្រងកម្មវិធី និង/ឬ អ្នកសម្របសម្រួលកម្រង/វិស័យ អំពីពិធីសារនានាសម្រាប់បង្ការការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។ ក្នុងករណីដែលទីភ្នាក់ងាររបស់អ្នកពុំមានពិធីសារដែលត្រូវបានបង្កើតឡើងសម្រាប់ PSEA ទេនោះ ចូរពិចារណាទាក់ទងទៅជនបង្គោល PSEA ដើម្បីសុំការណែនាំសម្រាប់បរិបទរបស់អ្នក។

### ការហាត់អនុវត្តឱ្យទទួលបាននូវភាពល្អឥតខ្ចោះ

- ចូរបន្សាំខ្លួនអ្នកដើម្បីឱ្យមានភាពងាយស្រួលទៅនឹង**គំរូអត្ថបទនៅទំព័រ ៧-១០។** ចូរហាត់អនុវត្តឮៗ ឬ អនុវត្តជាមួយសហការី និងមិត្តភក្តិ។ កាលណាអ្នកអនុវត្តកាន់តែច្រើន អ្នកក៏នឹងកាន់តែមានភាពងាយស្រួលផងដែរ នៅពេលដែលជនរងគ្រោះនៃ GBV សុំឱ្យអ្នកជួយ។
- សូមមើល**សៀវភៅណែនាំស្តីពីគន្លឹះ**សម្រាប់អ្នកប្រើប្រាស់ ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីរបៀបដែលអ្នកអាចបណ្តុះបណ្តាល/អនុវត្តសម្ភារៈទាំងនេះ។
- **កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ** មានសារៈប្រយោជន៍ចំពោះអ្នកដែលកំពុងជួបប្រទះស្ថានភាពពិបាក។ លើកក្រោយ នៅពេលដែលសហការី ឬ មិត្តភក្តិរបស់អ្នកមកសុំឱ្យអ្នកផ្តល់កិច្ចគាំទ្រ ឬការណែនាំ ចូរហាត់អនុវត្តដោយប្រើប្រាស់សំនួរ និង ប្រយោគនៅក្នុងឯកសារនេះ។

## មើល

**នៅពេលដែលនរណាម្នាក់ប្រាប់អ្នកឱ្យដឹងអំពីបទពិសោធន៍នៃអំពើហិង្សាទាក់ទងនឹងយេនឌ័ររបស់ពួកគេឱ្យអ្នកបានដឹង....**

### ណែនាំខ្លួនអ្នកឱ្យគេស្គាល់

- ណែនាំដោយប្រាប់អំពីឈ្មោះរបស់អ្នក តួនាទីរបស់អ្នក និង តើអ្នកជានរណា។ ចូរសួរថាតើអ្នកអាចជួយបានដោយរបៀបណា។

### ដោះស្រាយបញ្ហាសេចក្តីត្រូវការមូលដ្ឋានបន្ទាន់

- មនុស្សម្នាក់ៗនឹងមានសេចក្តីត្រូវការមូលដ្ឋានផ្សេងៗគ្នា ដែលអាចរួមមានការថែទាំសុខភាពជាបន្ទាន់ ទឹកផឹក ការស្វែងរកមនុស្សជាទីស្រឡាញ់ ឬ ភួយ ឬ សម្លៀកបំពាក់ ប្រសិនបើមានការបាត់បង់ ឬ រហែក ប្រឡាក់ ឬ ត្រូវបានគេដោះចេញ។ ជាពិសេស ចំពោះជនរងគ្រោះនៃ GBV សម្លៀកបំពាក់អាចជាសេចក្តីត្រូវការបន្ទាន់សម្រាប់ពួកគេ ដើម្បីឱ្យពួកគេមានអារម្មណ៍កាន់តែមានផាសុកភាព

និងមានភាពថ្លៃថ្នូរ។

- ចូរអនុញ្ញាតឱ្យជនរងគ្រោះប្រាប់អ្នកអំពីអារម្មណ៍របស់ពួកគេ ចំពោះបញ្ហាសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ។ ចូរប្រុងប្រយ័ត្នដោយមិនត្រូវធ្វើការសន្និដ្ឋានផ្អែកលើអ្វីដែលអ្នកកំពុងមើលឃើញឡើយ។

## ត្រូវដឹងអំពីវិធីផ្សេងៗគ្នាដែលមនុស្សធ្វើការទាក់ទងដើម្បីសុំកិច្ចគាំទ្រ

- អនុញ្ញាតឱ្យជនរងគ្រោះបង្ហាញអំពីអារម្មណ៍របស់ពួកគេក្នុងទម្រង់ណាក៏បាន។ មនុស្សយើងមានការឆ្លើយតបផ្សេងៗគ្នាទៅនឹងអារម្មណ៍តានតឹង និងវិបត្តិ។ មនុស្សមួយចំនួនអាចមានភាពស្ងៀមស្ងាត់ និង និយាយមិនចេញ ដោយឡែកអ្នកខ្លះទៀតបង្ហាញអារម្មណ៍ខឹងសម្បារ និងស្រែកគំហក បន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើងចំពោះខ្លួន យំសោក ហិង្សា។ល។
- ជនពិការ អ្នកដែលនិយាយភាសាផ្សេង និងអ្នកដទៃទៀតដែលជួបប្រទះឧបសគ្គរាំងស្ទះផ្សេងៗគ្នា នៅពេលទាក់ទងដើម្បីសុំការគាំទ្រ។ ចូរប្រកាន់ខ្ជាប់គោលការណ៍ដែលផ្តោតលើជនរងគ្រោះ និង ការរក្សាការសម្ងាត់ នៅពេលស្វែងរកវិធីដើម្បីស្តាប់ និង គាំទ្រជនទាំងនេះ។ បើទោះបីជាអ្នកមិនអាចយល់អំពីនរណាម្នាក់បានក៏ដោយ ប៉ុន្តែអ្នកអាចបង្ហាញឱ្យឃើញអំពីការយកចិត្តទុកដាក់ និង ការគាំទ្រជានិច្ច។
- ធានាថាមានវត្តមានបុគ្គលិកជាស្ត្រី ដើម្បីផ្តល់កិច្ចគាំទ្រ ជាពិសេសនៅក្នុងបរិបទវប្បធម៌ដែលស្ត្រី និង/ឬ កុមារីមិនអាចប្រាស្រ័យទាក់ទងជាមួយបុរសបាន។

## ទទួលស្គាល់អំពីអ្វីដែលអ្នកអាច និង មិនអាចគ្រប់គ្រងបាន

- ស្ថានភាពមួយចំនួនទាមទារឱ្យមានកិច្ចគាំទ្រឯកទេសដែលហួសពីតួនាទីរបស់អ្នក ដូចជាស្ថានភាពដែលពាក់ព័ន្ធនឹងកុមារ ការផ្តល់របាយការណ៍ជាកាតព្វកិច្ច [3] គ្រោះថ្នាក់ភ្លាមៗចំពោះជនរងគ្រោះ ឬក្នុងករណីដែលជនរងគ្រោះអាចបង្កគ្រោះថ្នាក់ចំពោះខ្លួនឯង ឬចំពោះអ្នកដទៃ។ អាចមានជនបង្គោលដទៃទៀត ដែលមានសមត្ថភាពផ្តល់កិច្ចគាំទ្របានល្អជាង នៅក្នុងសេណារីយ៉ូនេះ។ សូមមើល **ឯកសារព័ត៌មានរបស់អ្នក** (ទំព័រ ៥ និង ៦) ។

**ចងចាំថា៖** ប្រសិនបើអ្នកចង់ស្វែងរកកិច្ចគាំទ្រពីប្រធានក្រុម ឬ អ្នកអនុវត្តការងារផ្នែកមនុស្សធម៌ដទៃទៀត **ត្រូវសុំការអនុញ្ញាតពីជនរងគ្រោះជាមុនជានិច្ច។** ចូរប្រាប់ជនរងគ្រោះឱ្យដឹងថាតើអ្នកចង់និយាយជាមួយនរណា ហេតុអ្វីបានជាអ្នកចង់និយាយជាមួយគាត់ និង តើអ្នកចង់ចែករំលែកព័ត៌មានអ្វីខ្លះ។ ប្រសិនបើជនរងគ្រោះពុំមានអារម្មណ៍ងាយស្រួល ឬ ប្រកែកភ្លាមៗចំពោះការចែករំលែកព័ត៌មានរបស់ពួកគេ ចូរជួយដល់ពួកគេឱ្យអស់ពីលទ្ធភាពរបស់អ្នក ដោយប្រើប្រាស់ឧបករណ៍នៅក្នុងកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំនេះ។

3 *មានបរិបទមួយចំនួន ដែលមានវិធាននៃការផ្តល់របាយការណ៍ជាកាតព្វកិច្ច ទាក់ទងនឹងប្រភេទករណីជាក់លាក់មួយចំនួន។ សូមសាកសួរជនបង្គោលទទួលបន្ទុកកិច្ចការពារ និង/ឬ អ្នកឯកទេសផ្នែក GBV សម្រាប់ព័ត៌មាន និងការណែនាំបន្ថែម។*

# ស្តាប់

ក្រោយពេលធានាបាននូវសេចក្តីត្រូវការមូលដ្ឋានរបស់ជនរងគ្រោះ ហើយជនរងគ្រោះលែងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ភ្លាមៗហើយនោះ **ចូរស្តាប់។**

ជនរងគ្រោះអាចមានអារម្មណ៍ក្រៀមក្រំ និង/ឬ ភាន់ភាំងខ្លាំង ប៉ុន្តែក្នុងនាមជាអ្នកផ្តល់ជំនួយ អ្នកចាំបាច់ត្រូវបន្តមានអារម្មណ៍ស្ងប់បំផុត ទៅតាមដែលអាចធ្វើបាន។ ចូរអនុញ្ញាតឱ្យជនរងគ្រោះចែករំលែកព័ត៌មានតិច ឬច្រើន ទៅតាមអ្វីដែលគាត់ចង់ចែករំលែក។ អ្នកពុំមានតួនាទី ផ្តល់ប្រឹក្សាយោបល់ នាំជនរងគ្រោះទៅទទួលសេវា ឬ ធ្វើកិច្ចសម្ភាសលម្អិតអំពីអ្វីដែលបានកើតឡើងចំពោះពួកគេទេ។ ជំនួសឱ្យការសួរសំនួរលម្អិតអំពីហេតុការណ៍ ចូរផ្តោតលើការផ្តល់ព័ត៌មានជូនពួកគេ អំពីសេវាដែលអ្នកដឹងថាមាន។

**គន្លឹះ៖**

**ជាធម្មតា ល្អបំផុតត្រូវជៀសវាងសួរសំនួរ ជាពិសេសសំនួរដែលចាប់ផ្តើមដោយពាក្យថា "ហេតុអ្វី" អាស្រ័យដោយសំនួរបែបនេះអាចធ្វើឱ្យមានអារម្មណ៍ថាគេកំពុងបន្ទោសជនរងគ្រោះ។ ជំនួសឱ្យការសួរសំនួរបែបនេះ ចូរយកចិត្តទុកដាក់ស្តាប់ និង ប្រសិនបើចាំបាច់ ចូរសួរសំនួរដូចជា "តើខ្ញុំអាចប្រាប់អ្នកអំពីសេវាដែលមាន សម្រាប់គាំទ្រអ្នក បានដែរឬទេ ?" ឬ "តើអ្នកចង់ឱ្យខ្ញុំគាំទ្រអ្នកយ៉ាងដូចម្តេច ?"**

**ឥទ្ធិពលនៃការស្តាប់៖**

ជួនកាល អ្នកអាចស្ថិតនៅក្នុងស្ថានភាពមួយដែលគ្មានសេវា ឬ ធនធាន ដែលអ្នកអាចចែករំលែកជាមួយជនរងគ្រោះបានទាល់តែសោះ។ អ្នកអាចមានអារម្មណ៍ថាមិនអាចជួយអ្វីបាន។ អ្នកចាំបាច់ត្រូវមានភាពស្មោះត្រង់ចំពោះជនរងគ្រោះ ដោយត្រូវទទួលស្គាល់សេចក្តីក្លាហានរបស់ជនរងគ្រោះដែលបានចែករំលែកបទពិសោធន៍របស់ពួកគេជាមួយអ្នក បង្ហាញឱ្យដឹងថា អ្នកមានអារម្មណ៍សោកស្តាយដែលមិនអាចជួយអ្វីបានច្រើនជាងនេះ និងផ្តល់ឱ្យជនរងគ្រោះនូវភាពថ្លៃថ្នូរឱ្យបានច្រើនបំផុតទៅតាមដែលអាចធ្វើបានក្នុងពេលសន្ទនា។ ការដែលមានវត្តមាន និងបង្ហាញឱ្យឃើញអំពីការស្តាប់ដោយយកចិត្តទុកដាក់ គឺជាសកម្មភាពដែលផ្តល់នូវកិច្ចគាំទ្ររួចទៅហើយ។

# ភ្ជាប់ទំនាក់ទំនង

ខណៈពេលដែលអ្នកគាំទ្រជនរងគ្រោះ ឱ្យធ្វើការសម្រេចចិត្តអំពីជំហានបន្ទាប់របស់ពួកគេ...

**ចូរសួរជនរងគ្រោះថាតើមាននរណាម្នាក់ដែលគាត់ទុកចិត្តដែលអាចទាក់ទងបាន ដើម្បីផ្តល់ការគាំទ្រ ដែរឬទេ។**

→ ប្រសិនបើជនរងគ្រោះសួរយោបល់របស់អ្នក សូមលើកទឹកចិត្តជនរងគ្រោះឱ្យធ្វើការសម្រេចចិត្តថាតើគួរទាក់ទងទៅនរណា នៅពេលណា និងហេតុអ្វី។

- មិនត្រូវផ្ដល់យោបល់ផ្ទាល់ខ្លួនរបស់អ្នកចំពោះស្ថានភាពឡើយ។

**ប្រសិនបើមានសេវាមួយចំនួន សូមផ្ដល់ព័ត៌មានត្រឹមត្រូវជូនជនរងគ្រោះអំពីសេវាដែលមាន ឬជម្រើសនានាដើម្បីឱ្យកាន់តែមានផាសុកភាព។**

- ការរៀបចំគឺជាគន្លឹះដ៏សំខាន់។ ចូរប្រើប្រាស់ **ឯកសារព័ត៌មានរបស់អ្នក** ( ***ទំព័រ ៥ និង ៦*** ) និងធានាថាអ្នកមានព័ត៌មានត្រឹមត្រូវប្រកបដោយបច្ចុប្បន្នភាព អំពីសេវាដែលមាន និងរបៀបទទួលបានសេវាទាំងនោះ។
- ប្រសិនបើអ្នកមិនប្រាកដថាមាន ឬ មិនមានសេវាជាក់លាក់ណាមួយទេនោះ ចូរនិយាយថាអ្នកមិនប្រាកដនោះទេ។

## បញ្ចប់កិច្ចសន្ទនាដោយការយល់ចិត្ត

- រក្សាការសម្ងាត់។
- ផ្ដល់ការបញ្ជាក់ប្រកបដោយភាពវិជ្ជមានចំពោះការសម្រេចចិត្តរបស់ជនរងគ្រោះ។
- សូមចងចាំថាតួនាទីរបស់អ្នកគឺផ្ដល់ការគាំទ្រដល់ជនរងគ្រោះចំពោះការសម្រេចចិត្ត និងជម្រើសរបស់ពួកគេ ឬ សូម្បីតែជនរងគ្រោះមិនធ្វើការសម្រេចចិត្ត ឬ ធ្វើការជ្រើសរើសអ្វីក៏ដោយ។ មិនត្រូវជួបជាមួយជនរងគ្រោះម្ដងហើយម្ដងទៀត ផ្ដល់ប្រឹក្សាយោបល់ ឬ ប៉ុនប៉ង ធ្វើការគ្រប់គ្រងករណីរបស់ជនរងគ្រោះឡើយ។

## ក្រោយកិច្ចសន្ទនា

**ការឆ្លុះបញ្ចាំង និងការថែទាំខ្លួនឯង៖** ចាំបាច់ត្រូវចងចាំថា អ្នកអាចធ្វើអ្វីៗគ្រប់យ៉ាងបានត្រឹមត្រូវ ប៉ុន្តែអ្នកមិនអាចដោះស្រាយបទពិសោធន៍ដែលមនុស្សម្នាក់នេះបានជួបប្រទះ ឬ បំបាត់ការឈឺចាប់របស់គាត់បានឡើយ។ ការស្ដាប់បទពិសោធន៍ដែលអ្នកដទៃបានជួបប្រទះ អាចធ្វើឱ្យអ្នកទទួលរងនូវបទពិសោធន៍នៃការឈឺចាប់ និង ការប៉ះទង្គិចផ្លូវចិត្តរបស់ពួកគេ ដែលចំណុចនេះត្រូវបានគេស្គាល់ថាជាការប៉ះទង្គិចផ្លូវចិត្តដោយប្រយោល។ ចូរគិតអំពីរបៀបថែទាំខ្លួនអ្នក នៅពេលដែលអារម្មណ៍ទាំងនេះជ្រៀតចូលក្នុងខ្លួនអ្នក។ ចូរទាក់ទងទៅប្រព័ន្ធ និង បណ្ដាញគាំទ្ររបស់អ្នក រាប់បញ្ចូលទាំងសហការី ប្រធានក្រុម ឬ អ្នកឯកទេសផ្នែក GBV ដើម្បីសុំការណែនាំ (ដោយត្រូវចងចាំអំពីការរក្សាការសម្ងាត់របស់ជនរងគ្រោះ) និង ស្វែងរកកិច្ចគាំទ្រ។

អាស្រ័យដោយប្រភេទមួយចំនួននៃអំពើហិង្សា (ឧទាហរណ៍ អំពើហិង្សាក្នុងគ្រួសារ) អាចមានដំណើរការជាវដ្ដនៃអំពើហិង្សា អ្នកអាចមើលឃើញមនុស្សម្នាក់នេះម្ដងទៀត ឬ ដឹងថាពួកគេទទួលរងហេតុការណ៍ហិង្សាដទៃទៀត។ អ្នកមិនអាចផ្លាស់ប្ដូរបទពិសោធន៍របស់ពួកគេបានឡើយ ប៉ុន្តែអ្នកអាច៖

- ស្ដាប់ជនរងគ្រោះដោយមិនធ្វើការវិនិច្ឆ័យក្នុងអំឡុងពេលនៃហេតុការណ៍នីមួយៗ មិនចំពោះថាអ្នកធ្លាប់ ឬ មិនធ្លាប់និយាយជាមួយពួកគេពីមុនមកឡើយ។
- គិតអំពីរបៀបកែលម្អការរៀបចំកម្មវិធីរបស់អ្នក ធ្វើឱ្យសេវាដែលអ្នកផ្ដល់ជូនកាន់តែមានសុវត្ថិភាព និង បង្កើតឱ្យមានបរិយាកាសវិជ្ជមាន សម្រាប់អ្នកដែលទទួលរងបទពិសោធន៍ GBV។

# ការគាំទ្រកុមារ និង ក្មេងជំទង់អាយុក្រោម១៨ឆ្នាំ

## សារគន្លឹះ

- ⋯→ **ត្រូវពិភាក្សា**ជាមួយអ្នកឯកទេសផ្នែក GBV ឬ ផ្នែកកិច្ចការពារកុមារនៅក្នុងប្រទេស/បរិបទរបស់អ្នកជាមុនជានិច្ច ដើម្បីស្វែងយល់អំពី៖ (១) តើមានសេវាអ្វីខ្លះនៅក្នុងតំបន់របស់អ្នក និង (២) ពិធីសារ និង នីតិវិធីក្នុងមូលដ្ឋាន។[4]
- ⋯→ **មិនបង្កគ្រោះថ្នាក់៖** មិនត្រូវស្វែងរកកុមាររងគ្រោះឡើយ។ វាមិនមែនជាការងាររបស់អ្នកក្នុងការស៊ើបអង្កេត ឬ ប៉ាន់ប្រមាណថាតើកុមារ/ក្មេងជំទង់ម្នាក់ កំពុងទទួលរងអំពើហិង្សានោះទេ។ ការធ្វើបែបនេះអាចនាំឱ្យកាន់តែមានអំពើហិង្សា និង ហានិភ័យចំពោះកុមារ/ក្មេងជំទង់។ ត្រូវបង្កលក្ខណៈឱ្យគេអាចទាក់ទងបាន ប្រសិនបើកុមារ/ក្មេងជំទង់ចង់ស្វែងរកជំនួយពីអ្នក។
- ⋯→ **ចងចាំអំពីតួនាទីរបស់អ្នក៖** ប្រសិនបើកុមារ/ក្មេងជំទង់ម្នាក់ ទាក់ទងអ្នកដើម្បីសុំជំនួយ
  - ១ ចូរស្តាប់ដោយមិនធ្វើការវិនិច្ឆ័យ។
  - ២ គាំទ្រកុមារ/ក្មេងជំទង់ ដោយការភ្ជាប់ទំនាក់ទំនងពួកគេទៅមនុស្សពេញវ័យម្នាក់ដែលកុមារ/ក្មេងជំទង់ កំណត់ថាជាអ្នកដែលមានសុវត្ថិភាព និងទុកចិត្តបាន។ មនុស្សម្នាក់នោះអាចមិនមែនជាឪពុកម្តាយ អ្នកថែទាំ ឬ សមាជិកគ្រួសាររបស់ពួកគេ។
  - ៣ មិនត្រូវសម្រេចចិត្តជំនួសពួកគេឡើយ រាប់បញ្ចូលទាំងការដែលមិនត្រូវបង្ខំឱ្យអ្នកថែទាំរបស់កុមារ/ក្មេងជំទង់ ឬ បុគ្គលដទៃទៀតនៅជាមួយពួកគេ នៅពេលដែលពួកគេនិយាយជាមួយអ្នក។
- ⋯→ **ផ្តល់ភាពងាយស្រួល៖** អនុញ្ញាតឱ្យកុមារ/ក្មេងជំទង់ដឹកនាំកិច្ចសន្ទនា បើទោះបីជាការធ្វើបែបនេះមានន័យថាជាការស្ថិតនៅអមជាមួយកុមារដោយស្ងៀមស្ងាត់ក៏ដោយ។ ត្រូវអង្គុយក្នុងកម្រិតស្មើភ្នែកគ្នាជាមួយកុមារ ព្រមជាមួយនឹងភាសាកាយវិការ ដើម្បីបង្ហាញទៅកុមារ/ក្មេងជំទង់ថាពួកគេអាចប្រាប់អំពីរឿងរ៉ាវគ្រប់យ៉ាងមកអ្នកបាន ប្រសិនបើគេចង់ប្រាប់។ មិនត្រូវសាកសួរសំនួរអំពីអ្វីដែលបានកើតឡើង នរណាជាអ្នកប្រព្រឹត្ត និងហេតុអ្វីឡើយ។ ដោយឡែក ចូរប្រើប្រយោគនិយាយលួងលោម និង និយាយក្នុងលក្ខណៈដែលពួកគេអាចយល់បាន។

**ចូរចងចាំ!** ៖ ប្រសិនបើមានតួអង្គដែលធ្វើការងារផ្នែក GBV ឬ ផ្នែកកិច្ចការពារកុមារ/ប្រកបញ្ជូន នៅក្នុងតំបន់របស់អ្នក ចូរសម្របសម្រួលឱ្យមានការបញ្ជូនកុមារ/ក្មេងជំទង់ប្រកបដោយសុវត្ថិភាព និងរក្សាការសម្ងាត់ ទៅអ្នកឯកទេស ដើម្បីជួយពួកគេឱ្យបានកាន់តែប្រសើរ។
ចូរប្រើមគ្គុទ្ទេសក៍ណែនាំនេះនៅពេលដែល**គ្មានតួអង្គដែលធ្វើការងារផ្នែក GBV ឬ ផ្នែកកិច្ចការពារកុមារ/ប្រកបញ្ជូន** នៅក្នុងតំបន់របស់អ្នក។

4 *សូមសាកសួរជនបង្គោលផ្នែក GBV ឬ ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមាររបស់អ្នកនៅក្នុងប្រទេស អំពីពិធីសារ និង នីតិវិធីក្នុងស្រុក ដោយរាប់បញ្ចូល៖ (១) ដែនកំណត់នៃការរក្សាការសម្ងាត់ និង (២) ជនបង្គោលដែលត្រូវបានកំណត់ភារកិច្ចឱ្យទទួលបន្ទុកការងារផ្នែក GBV និង កិច្ចការពារកុមារ។*

- **ប្រព្រឹត្តចំពោះកុមារគ្រប់រូបដោយស្មើភាពគ្នា៖** កុមារគ្រប់រូបគួរទទួលបានកិច្ចគាំទ្រដូចគ្នាឥតលម្អៀង ដោយមិនប្រកាន់អំពីភេទ អាយុ ស្ថានភាពគ្រួសារ ស្ថានភាពនៃអ្នកថែទាំរបស់ពួកគេ ឬ ចំណែកដទៃទៀតនៃអត្តសញ្ញាណរបស់ពួកគេ។ មិនត្រូវប្រព្រឹត្តចំពោះកុមារដែលបានទទួលរងបទពិសោធន៍ GBV ថាគ្មានអ្វីដែលអាចជួយពួកគេបានឡើយ។ កុមារម្នាក់ៗមានសមត្ថភាពពិសេស និងចំណុចខ្លាំងរៀងៗខ្លួន ព្រមទាំងមានសមត្ថភាពក្នុងការសះស្បើយឡើងវិញ។ ចូរនិយាយទៅកាន់កុមាររងគ្រោះក្នុងលក្ខណៈមួយដែលពួកគេអាចយល់បាន និង គោរពដល់ភាពថ្លៃថ្នូរ និង គំនិតរបស់ពួកគេ។
- **រក្សាការសម្ងាត់៖** មិនត្រូវកត់ត្រា ថតរូប ឬ ចងក្រងឯកសារក្នុងទម្រង់ណាមួយ អំពីការប្រាស្រ័យទាក់ទងរបស់អ្នកជាមួយកុមារ/ក្មេងជំទង់ឡើយ។ សូមដាក់ទូរស័ព្ទ ឬ កុំព្យូទ័រទៅឱ្យឆ្ងាយ ដើម្បីជៀសវាងកុំឱ្យជនរងគ្រោះយល់ថាអ្នកកំពុងថតកិច្ចសន្ទនា។ ចូរសុំការអនុញ្ញាតដើម្បីចែករំលែកព័ត៌មានអំពីកុមារ/ក្មេងជំទង់ ឬ បទពិសោធន៍ដែលពួកគេបានជួបប្រទះ។ ចំណុចនេះមានន័យថា អ្នកត្រូវសាកសួរ ថាតើអ្នកអាចចែករំលែកព័ត៌មានបានដែរឬទេ បើទោះបីជាចែករំលែកទៅអ្នកដែលកុមារ/ក្មេងជំទង់បានកំណត់ថាជាមនុស្សដែលពួកគេទុកចិត្តក៏ដោយ។
- **ធានាចំពោះសុវត្ថិភាពរបស់កុមារ៖** សុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ គឺជាក្តីបារម្ភចម្បង។ ចូរពិចារណាអំពីសុវត្ថិភាពរបស់កុមារនៅក្នុងរាល់ទំនាក់ទំនងទាំងអស់ជាមួយពួកគេ ព្រមទាំងពាក់ព័ន្ធនឹងជំហានបន្ទាប់នានាដែលនឹងត្រូវធ្វើឡើងផងដែរ។

**!**

ក្នុងករណីមួយចំនួន អ្នកអាចមិនប្រាកដអំពីរបៀបគាំទ្រ**ឧត្តមប្រយោជន៍របស់កុមារ** និង សុខុមាលភាពផ្លូវកាយ និង ផ្លូវចិត្តរបស់កុមារ។ ប្រសិនបើអ្នកមិនប្រាកដអំពីសុវត្ថិភាពនៃស្ថានភាពណាមួយ ចូរប្រាប់កុមារថា អ្នកត្រូវការពិគ្រោះដោយសម្ងាត់ជាមួយអ្នកផ្តល់សេវាម្នាក់ទៀតដែលអាចមានចំណេះដឹងខ្ពស់ជាង អំពីរបៀបធានាសុវត្ថិភាពពួកគេ។[4]

- **ត្រូវដឹងអំពីរបៀបដែលកុមារ/ក្មេងជំទង់ ឬ អ្នកថែទាំរបស់ពួកគេ អាចស្វែងរកការគាំទ្រ៖** កុមារ និង ក្មេងជំទង់អាចស្វែងរកជំនួយក្នុងលក្ខណៈខុសពីមនុស្សពេញវ័យ ហើយពួកគេកម្រធ្វើការបើកចំហរដោយផ្ទាល់ណាស់។ កុមារអាចមានការពិបាកក្នុងការទុកចិត្ត ឬ និយាយជាមួយមនុស្សពេញវ័យ (ជាពិសេសមនុស្សពេញវ័យដែលពួកគេមិនស្គាល់ច្បាស់) ទទួលរងបទពិសោធន៍នៃការភ័យខ្លាច ការខ្មាសអៀន ឬ អាម៉ាស់ ឬ ភ័យខ្លាចក្នុងការបង្ហាញអំពីអារម្មណ៍របស់ពួកគេ។ អ្នកអាច៖ (១) បានឮពាក្យចចាមអារាមអំពីករណីរំលោភបំពានកុមារ (២) មានមនុស្សពេញវ័យទាក់ទងអ្នកដើម្បីសុំជំនួយសម្រាប់កុមារ ឬ (៣) សង្ស័យថាមានករណីរំលោភបំពានកុមារ ដោយផ្អែកលើសញ្ញា ឬ អាកប្បកិរិយារបស់កុមារ។

| អ្វីដែលត្រូវធ្វើ | អ្វីដែលមិនត្រូវធ្វើ |
| --- | --- |
| **ប្រសិនបើមាននរណាម្នាក់សុំឱ្យអ្នកជួយ សម្រាប់ករណីកុមារ/ក្មេងជំទង់ដែលត្រូវការជំនួយ....** | |
| ✓ ត្រូវផ្តល់ព័ត៌មានដែលត្រឹមត្រូវ និងមានបច្ចុប្បន្នភាព អំពីសេវាដែលមាន ជូនបុគ្គលដែលសុំអ្នកឱ្យផ្តល់ការគាំទ្រ។<br>✓ ត្រូវគោរពគោលការណ៍រក្សាការសម្ងាត់។ | × មិនត្រូវស៊ើបអង្កេតករណីពាក្យចចាមអារាម ឬ ខិតខំស្វែងរក/សម្ភាសកុមារ/ក្មេងជំទង់ឡើយ។<br>× មិនត្រូវពិភាក្សា ឬ ចែករំលែកព័ត៌មានលម្អិតអំពីអ្វីដែលអ្នកបានដឹង ជាមួយនរណាម្នាក់ឡើយ។ |
| **ប្រសិនបើកុមារ/ក្មេងជំទង់សុំឱ្យអ្នកជួយ....** | |
| **មើល** | |
| ✓ ត្រូវសួរកុមារ/ក្មេងជំទង់ ថាតើពួកគេចង់រកកន្លែងដែលស្ងាត់ និងមានភាពឯកជនដើម្បីនិយាយគ្នាដែរឬទេ។ ត្រូវប្រាកដថាវាគឺជាកន្លែងដែលអ្នកដទៃអាចមើលឃើញអ្នក ប៉ុន្តែ ស្តាប់អ្នកមិនលឺ។<br>✓ ត្រូវធានាថាអ្នកអង្គុយក្នុងកម្រិតស្មើភ្នែកគ្នាជាមួយកុមារ។ ត្រូវរក្សាភាសាកាយវិការបើកចំហរ។<br>✓ ត្រូវសួរទៅកុមារី និងកុមារា ថាតើពួកគេចង់និយាយជាមួយមនុស្សពេញវ័យជាស្ត្រី ឬ បុរស ដែលមានភេទដូចគ្នាទៅនឹងពួកគេ ដែរឬទេ។ | × មិនត្រូវបង្ខាប់កុមារ/ក្មេងជំទង់ឱ្យទៅកន្លែងស្ងាត់ ឬ កន្លែងឯកជន ឬ ដាក់កុមារឱ្យស្ថិតនៅដាច់ដោយឡែកផ្ទុយពីឆន្ទៈរបស់ពួកគេឡើយ។<br>× មិនត្រូវប៉ះពាល់ ឱប ឬ មានទំនាក់ទំនងរាងកាយឡើយ អាស្រ័យដោយការធ្វើបែបនេះអាចបង្កការបាក់ស្មារតី ធ្វើឱ្យមានអារម្មណ៍មិនងាយស្រួល និង មានអារម្មណ៍តានតឹង។ |
| **ស្តាប់** | |
| ✓ ត្រូវស្តាប់ដោយយកចិត្តទុកដាក់ និង កត់សម្គាល់ចំពោះទំនាក់ទំនងតាមរយៈភាសាកាយវិការ។<br>✓ ត្រូវមានភាពស្ងប់ស្ងាត់ និង អត់ធ្មត់ ដោយទទួលយកអ្វីដែលគេកំពុងនិយាយ ដោយមិនធ្វើការវិនិច្ឆ័យ។<br>✓ ត្រូវអនុញ្ញាតឱ្យកុមារ/ក្មេងជំទង់រៀបរាប់ដោយខ្លួនឯង និង ប្រើប្រាស់ពាក្យពេជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ | × មិនត្រូវធ្វើការសម្ភាស ឬ ប៉ាន់ប្រមាណ។ មិនត្រូវកត់ត្រា ថតរូប ឬ ចែករំលែកព័ត៌មានតាមរយៈពាក្យសម្តី អំពីកុមារ/ក្មេងជំទង់ ឬ បទពិសោធន៍ដែលពួកគេបានជួបប្រទះ។[4]<br>× មិនត្រូវបង្ហាញអារម្មណ៍រន្ធត់ ការមិនជឿ កំហឹង ឬ ប្រតិកម្មដទៃទៀត ដែលអាចបង្កឱ្យកុមារ/ក្មេងជំទង់មានអារម្មណ៍តានតឹងឡើយ។<br>× មិនត្រូវប្រើពាក្យវប្បធម៌ខ្ពស់ៗ ឬ និយាយច្រើនជាងកុមារ/ក្មេងជំទង់ឡើយ។ |

| អ្វីដែលត្រូវធ្វើ | អ្វីដែលមិនត្រូវធ្វើ |
| --- | --- |

## លួងលោម

| | |
| --- | --- |
| ✓ ត្រូវបញ្ជាក់ប្រាប់កុមារ/ក្មេងជំទង់ថា វាមិនអីនោះទេដែលពួកគេប្រាប់អ្នកអំពីអ្វីដែលបានកើតឡើង។<br>✓ ត្រូវគោរពការយល់ឃើញ ជំនឿ និងគំនិតរបស់កុមារ។ | × មិនត្រូវធ្វើការសន្យាដែលអ្នកមិនអាចធ្វើបាននោះទេ ដូចជាការនិយាយថា "គ្រប់យ៉ាងនឹងមិនអីនោះទេ" នៅពេលដែលអ្វីទាំងនោះមិនស្ថិតក្រោមការគ្រប់គ្រងរបស់អ្នក ក្នុងការធានា សុខុមាលភាពរបស់កុមារ។<br>× មិនត្រូវបង្ខំកុមារ/ក្មេងជំទង់ឱ្យបន្តនិយាយជាមួយអ្នកឡើយ ប្រសិនបើកុមារមិនចង់។ |

**ត្រូវប្រើប្រយោគលួងលោមដែលសមស្របទៅតាមបរិបទវប្បធម៌....ឧទាហរណ៍ដូចជា៖**

- "ខ្ញុំជឿអ្នក" - កសាងការជឿទុកចិត្ត
- "ខ្ញុំរីករាយដែលអ្នកបានប្រាប់ខ្ញុំឱ្យដឹង" - កសាងទំនាក់ទំនងជាមួយកុមារ
- "អរគុណដែលបានចែករំលែកបទពិសោធន៍ដែលអ្នកបានជួបប្រទះ" - បង្ហាញអំពីការយល់ចិត្ត
- "អ្នកក្លាហានណាស់ដែលនិយាយជាមួយខ្ញុំ" - ផ្តល់ការបញ្ជាក់ និង ផ្តល់ភាពអង់អាច

## ភ្ជាប់ទំនាក់ទំនង

| | |
| --- | --- |
| ✓ ត្រូវសួរថាតើមាននរណាម្នាក់ដែលកុមារ/ក្មេងជំទង់ទុកចិត្តដែរឬទេ និង តើកុមារ/ក្មេងជំទង់ចង់បានជំនួយក្នុងការទាក់ទងទៅមនុស្សម្នាក់នេះដែរឬទេ ឬ ចង់ឱ្យអ្នកអមដំណើរជាមួយដើម្បីស្វែងរកមនុស្សម្នាក់នេះដែរឬទេ។<br>✓ ត្រូវបន្តនៅជាមួយកុមារ/ក្មេងជំទង់រហូតដល់ពេលដែលពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព ឬ ស្ថិតក្រោមការថែទាំរបស់នរណាម្នាក់ដែលពួកគេកំណត់ថាជាមនុស្សដែលមានសុវត្ថិភាព និងទុកចិត្តបាន។<br>✓ ត្រូវផ្តល់ឱ្យកុមារ/ក្មេងជំទង់ និង មនុស្សពេញវ័យដែលពួកគេទុកចិត្ត នូវព័ត៌មានត្រឹមត្រូវ និង មានភាពពាក់ព័ន្ធ អំពីសេវាដែលមាន និងរបៀបទទួលបានសេវាទាំងនោះ។<br>✓ ត្រូវនិយាយអ្វីដែលអ្នកដឹង និង អ្វីដែលអ្នកមិនដឹង។ និយាយថា "ខ្ញុំមិនដឹង" ឬ "ខ្ញុំមិនមានព័ត៌មាននោះទេ" ប្រសិនបើអ្នកពុំមានព័ត៌មានដែលគេស្នើសុំ។ | × មិនត្រូវបង្ខំកុមារ/ក្មេងជំទង់ឱ្យនាំអ្នកថែទាំរបស់ពួកគេ ឬ អ្នកដទៃទៀតមកជាមួយ នៅពេលនិយាយជាមួយអ្នកឡើយ អាស្រ័យដោយអ្នកទាំងនេះអាចជាអ្នកដែលបានប្រព្រឹត្តអំពើហិង្សា ឬ កុមារ/ក្មេងជំទង់អាចមិនចង់ចែករំលែកអំពីបទពិសោធន៍ដែលពួកគេបានជួបប្រទះ ជាមួយអ្នកទាំងនោះ។<br>× មិនត្រូវទុកកុមារ/ក្មេងជំទង់ចោលដោយគ្មានការយកចិត្តទុកដាក់ឡើយ ខណៈពេលដែលពួកគេកំពុងមានអារម្មណ៍តានតឹង (ឧទាហរណ៍ កំពុងយំ ខឹង ឬ រន្ធត់ចិត្ត)។<br>× មិនត្រូវព្យាយាមដោះស្រាយស្ថានភាពដោយខ្លួនឯង រៀបចំផែនការ ឬ សម្រេចចិត្តជំនួយកុមារ/ក្មេងជំទង់ឡើយ។ |

**ឯកសារយោងសម្រាប់អាយុ និងសមត្ថភាពរបស់កុមារក្នុងការសម្រេចចិត្ត**

សូមកត់សម្គាល់ថាអ្នកអនុវត្តការងារឯកទេសដែលមានបទពិសោធន៍ធ្វើការងារជាមួយកុមារ/ក្មេងជំទង់ដែលបានទទួលរងបទពិសោធន៍ GBV គឺជាអ្នកដែលសមស្របបំផុតក្នុងការកំណត់អំពីសមត្ថភាពរបស់កុមារក្នុងការសម្រេចចិត្ត ដោយមានការសម្របសម្រួលជាមួយកុមារ/ក្មេងជំទង់ផ្ទាល់ និង អ្នកថែទាំផ្សេងៗគ្នារបស់ពួកគេ។

**តួនាទីរបស់អ្នកដែលមិនមែនជាអ្នកឯកទេស គឺត្រូវស្តាប់ និង លួងលោមកុមារ/ក្មេងជំទង់ ភ្ជាប់ទំនាក់ទំនងពួកគេជាមួយនរណាម្នាក់ដែលពួកគេទុកចិត្ត និង ចែករំលែកព័ត៌មានអំពីសេវាដែលមាន។** ប្រភេទអាយុខាងក្រោម គឺសម្រាប់ប្រើប្រាស់ជាឯកសារយោងប៉ុណ្ណោះ ហើយវាអាចប្រែប្រួលទៅតាមអាយុ កម្រិតនៃភាពចាស់ទុំ ដំណាក់កាលអភិវឌ្ឍ និងកត្តាដទៃទៀត។

**ក្មេងជំទង់ដែលមានវ័យច្រើន ចាប់ពី១៥ឆ្នាំឡើងទៅ** ជាទូទៅមានភាពចាស់ទុំគ្រប់គ្រាន់ក្នុងការសម្រេចចិត្តដោយខ្លួនឯង និងយល់អំពីបទពិសោធន៍ដែលពួកគេបានជួបប្រទះ។

- ⇢ **តួនាទីរបស់អ្នក៖** (១) ស្តាប់ក្មេងជំទង់ចែករំលែកអំពីបទពិសោធន៍ដែលពួកគេបានជួបប្រទះ (២) គាំទ្រក្មេងជំទង់ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយអ្នកដែលពួកគេទុកចិត្ត ដើម្បីបន្តទទួលបានការគាំទ្រ និង (៣) ផ្តល់ព័ត៌មានអំពីសេវាដែលមាន និង របៀបទទួលបានសេវាទាំងនោះ។

**កុមារតូច អាយុចន្លោះពី ៦ ទៅ ៩ឆ្នាំ និង ក្មេងជំទង់តូច អាយុចន្លោះពី១០ ទៅ ១៤ឆ្នាំ** អាច ឬ មិនអាចរាយការណ៍ដោយខ្លួនឯងអំពីបទពិសោធន៍នៃអំពើហិង្សា។ ពួកគេប្រហែលជាអាច ឬ មិនអាចសម្រេចចិត្តដោយខ្លួនឯងបាន។

- ⇢ **តួនាទីរបស់អ្នក៖** (១) គាំទ្រកុមារ/ក្មេងជំទង់ក្នុងការស្វែងរកមនុស្សពេញវ័យដែលពួកគេទុកចិត្ត ដើម្បីគាំទ្រពួកគេចំពោះជំហានបន្ទាប់ និង (២) ផ្តល់ព័ត៌មានអំពីសេវាដែលមាន និង របៀបទទួលបានសេវាទាំងនោះ ជូនកុមារ/ក្មេងជំទង់ និង មនុស្សពេញវ័យដែលកុមារ/ក្មេងជំទង់បានកំណត់។

**ទារក និងកុមារអាយុពី ០ ទៅ ៥ឆ្នាំ** មិនអាចរាយការណ៍ដោយខ្លួនឯង អំពីបទពិសោធន៍នៃអំពើហិង្សាបានឡើយ ដោយសារពួកគេខ្វះជំនាញទំនាក់ទំនង។ មនុស្សម្នាក់ទៀត ដូចជាមិត្តភក្តិ អ្នកថែទាំ សមាជិកគ្រួសារ សមាជិកសហគមន៍។ល។ ទំនងនឹងស្វែងរកជំនួយ ជំនួសឱ្យកុមារ។

- ⇢ **តួនាទីរបស់អ្នក៖** ផ្តល់ព័ត៌មានជូនបុគ្គលដែលអមជាមួយកុមារ អំពីសេវាដែលមាន និង របៀបទទួលបានសេវាទាំងនោះ។

*កែសម្រួលពី៖ UNHCR, គោលការណ៍ណែនាំស្តីពីការកំណត់អំពីឧត្តមប្រយោជន៍ ២០០៨។ IRC/UNICEF, ការថែទាំកុមាររងគ្រោះនៃអំពើរំលោភបំពានផ្លូវភេទ ២០១២។*

**សៀវភៅមគ្គុទេសក៍នេះបានកែសម្រួលឱ្យស្របជាមួយបរិបទកម្ពុជា**
*បកប្រែជាភាសាខ្មែរ និងបោះពុម្ពផ្សាយដោយអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា ដោយផ្អែកលើច្បាប់ដើមជាភាសាអង់គ្លេស និងជាធនធានសកលដែលអន្តរស្ថាប័នបានអនុម័ត។*

ឯកសារនេះគឺជាមគ្គុទ្ទេសក៍ណែនាំសម្រាប់ភ្ជាប់ទៅនឹងគោលការណ៍ណែនាំ IASC GBV ឆ្នាំ២០១៥។
www.gbvguidelines.org

www.gbvguidelines.org/pocketguide

GET IT ON Google Play

Download on the App Store

GBV Pocket Guide